# សុន្ទរកថាបើក
# ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍
## ថ្លែងក្នុងពិធីបើកសន្និបាតបូកសរុបការងារទេសចរណ៍ ការបូកសរុបផែនការស្តារ និងលើកស្ទួយ វិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ដំណាក់កាលទី១ (២០២០-២០២១) និង ឆមាសទី១ ឆ្នាំ២០២២ និងលើកទិសដៅផែនការស្តារឡើងវិញនូវវិស័យទេសចរណ៍ ក្នុងដំណាក់កាលទី២ (ឆមាសទី២ ឆ្នាំ២០២២-២០២៣)
## ទីស្តីការក្រសួងទេសចរណ៍ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២

*សូមគោរព៖*

*- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីរាប់អាន*
*- អង្គសន្និបាតជាទីមេត្រី!*

ថ្ងៃនេះ តាងនាមឱ្យក្រសួងទេសចរណ៍ និងក្រុមការងាររាជរដ្ឋាភិបាល និងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីរីករាយដែលបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្នុង“**ពិធីបើកសន្និបាតបូកសរុបការងារទេសចរណ៍ ការបូកសរុបផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ដំណាក់កាលទី១(២០២០-២០២១) និងឆមាសទី១ ឆ្នាំ២០២២ និងលើកទិសដៅផែនការស្តារឡើងវិញនូវវិស័យទេសចរណ៍ក្នុងដំណាក់កាលទី២(ឆមាសទី២ ឆ្នាំ២០២២-២០២៣)**” ដ៏មានសារៈសំខាន់នាពេលនេះ។

ខ្ញុំសូមវាយតំលៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងទេសចរណ៍ និងក្រុមការងាររាជរដ្ឋាភិបាល និងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ក្នុងការបំពេញភារកិច្ចកន្លងមក ដែលបានប្រមូលផ្តុំនូវកំលាំងស្មារតី និងឆន្ទៈមោះមុតក្នុងការអនុវត្តនូវសកម្មភាពជាអាទិភាពនានាក្នុងផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ដើម្បីរក្សាបាននូវភាពធន់នៃវិស័យទេសចរណ៍កម្ពុជាក្នុងដំណាក់កាលវិបត្តិ ហើយបាននិងកំពុងឈានចូលដំណាក់កាលងើបឡើងវិញនាពេលនេះ ពិសេសធានាបាន កម្ពុជា ជាគោលដៅទេសចរណ៍សុវត្ថិភាព ប្រកបដោយគុណភាព និងបដិសណ្ឋារកិច្ចល្អ។

ជាការចាប់ផ្តើម ខ្ញុំសូមរំលឹកអំពីការវិវត្តនៃវិស័យទេសចរណ៍កម្ពុជា និងវឌ្ឍនភាពការងារ ស្តីពីការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ដូចតទៅ៖

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ, ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** វិស័យទេសចរណ៍កម្ពុជាបានលូតលាស់គួរឱ្យកត់សម្គាល់ និងបានបំពេញតួនាទីជាសសរស្តម្ភមួយយ៉ាងសំខាន់ សម្រាប់សេដ្ឋកិច្ចកម្ពុជា។ វិស័យទេសចរណ៍កម្ពុជា មានអត្រាកំណើនទេសចរអន្តរជាតិជាមធ្យម **១២%** ក្នុងមួយឆ្នាំៗ ក្នុងនោះ**ឆ្នាំ២០១៩** ជាឆ្នាំកំពូល នៃវិស័យទេសចរណ៍កម្ពុជា ដោយទទួលបានទេសចរអន្តរជាតិជាង **៦,៦ លាននាក់ កើនឡើង ៦%** បន្ថែមទៀត។ ជាអកុសល, ចាប់តាំងពីឆ្នាំ២០២០ និងឆ្នាំ២០២១,

វិស័យទេសចរណ៍បានធ្លាក់ចុះយ៉ាងខ្លាំងដោយសារឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ ដោយការបាត់បង់ការធ្វើដំណើរជាអន្តរជាតិ និងបានបណ្តាលឱ្យក្រុមហ៊ុនជាច្រើននៅក្នុងវិស័យនេះ កាត់បន្ថយ ផ្អាក ឬបិទអាជីវកម្មទាំងស្រុងតែម្តង ដែលជាហេតុនាំឱ្យបុគ្គលិករាប់ម៉ឺននាក់ ត្រូវបានព្យួរការងារ ឬបានបាត់បង់ការងារ និងប្រាក់ចំណូល ។

ក្នុងបរិការណ៍នៃការវិវត្តដ៏តានតឹងនេះ រាជរដ្ឋាភិបាលកម្ពុជាក្រោមដំបូលសន្តិភាព និងការដឹកនាំដ៏ឈ្លាសវៃមោះមុតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានខិតខំយ៉ាងសស្រាក់សស្រាំ ដើម្បីទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ តាមរយៈការដាក់ចេញជាបន្តបន្ទាប់នូវច្បាប់, បទប្បញ្ញត្តិ, វិធានការសុខាភិបាល, វិធានការរដ្ឋបាល និងវិធានការផ្សេងៗទៀត។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការអន្តរាគមន៍ និងវិធានការនានាជាបន្តបន្ទាប់ទៀត សម្រាប់ឆ្នាំ២០២២ នេះ ពិសេសវិធានការដើម្បីពង្រឹងភាពធន់, គាំទ្រ ជំរុញ និងស្តារវិស័យទេសចរណ៍ឡើងវិញ បានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ដែលដើរតួជាមូលដ្ឋានដ៏សំខាន់សម្រាប់ដំណាក់កាលនៃការងើបឡើងវិញនេះ។

ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្រសួងទេសចរណ៍ក៏បានដាក់ចេញវិធានការជាច្រើន ក្នុងក្របខណ្ឌនៃការចូលរួមទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ-១៩ ដូចជាៈ <u>ទី១</u>-ការដាក់ចេញនូវ**វិធានសុវត្ថិភាពទេសចរណ៍ ក្នុងដំណាក់កាលទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ-១៩** បានចំនួន **១២ សេវាកម្ម**, <u>ទី២</u>-ការដាក់ចេញ **"នីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា"** (SOP) សម្រាប់សេវាកម្មទេសចរណ៍ និងទីតាំងដែលមានឧបនិស្ស័យទាក់ទាញទេសចរណ៍ និងសម្រាប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯង តាមផ្លូវគោក ស្របតាមគន្លងប្រក្រតីភាពថ្មី ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ជំរុញចលនាទេសចរណ៍ក្នុងស្រុកផង ហើយក៏បម្រើដល់ការបើកទទួលទេសចរណ៍វ៉ាក់សាំងពេញលេញផងដែរ, និង **<u>ទី៣</u>-ការរៀបចំប្រព័ន្ធសិក្សាជំនាញទេសចរណ៍តាមអនឡាញ** (E-Learning) រួមបញ្ចូលទាំងការសិក្សាតាមអនឡាញសម្រាប់ពង្រឹងជំនាញដែលមានស្រាប់ និងការផ្តល់នូវជំនាញបន្ថែមដល់បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ និងការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល សម្រាប់បុគ្គលិកឯកជន ម្ចាស់អាជីវកម្ម សហគ្រិនក្នុងវិស័យទេសចរណ៍ និងមន្ត្រីទេសចរណ៍ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ហើយកាលពីដើមឆ្នាំនេះ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ យើងបានរៀបចំពិធីប្រកាស**បើកយុទ្ធនាការ "កម្ពុជាៈ ជាគោលដៅទេសចរណ៍សុវត្ថិភាព និងបៃតង"**, រួមជាមួយគោលការណ៍ណែនាំ **"អ្វីគួរធ្វើ និងមិនគួរធ្វើសម្រាប់ភ្ញៀវទេសចរមកដល់ព្រះរាជាណាចក្រកម្ពុជា"**, **ប្រព័ន្ធគ្រប់គ្រងសមត្ថភាពផ្ទុក** (Carrying Capacity) **សម្រាប់ហាង និងផ្សារ តាមគន្លងប្រក្រតីភាពថ្មី, និងនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ផ្សារទំនើបខ្នាតធំ ផ្សារទំនើបខ្នាតតូច ផ្សារមិនរៀបរយ និងផ្សារសាធារណៈ** ផងដែរ។

ក្នុងទិសដៅគាំទ្រ, ជំរុញ និងស្តារវិស័យសេដ្ឋកិច្ចឡើងវិញ ក្នុងក្របខណ្ឌនៃការកសាងគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ក្រសួងទេសចរណ៍ក៏បានរៀបចំឯកសារគោលសំខាន់ៗ រួមមានៈ <u>ទី១).</u> ផែនទីចង្អុលផ្លូវ ស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩, **<u>ទី២).</u>** ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥, **<u>ទី៣).</u>** ផែនការមេអភិវឌ្ឍន៍ទេសចរណ៍

ខេត្តមណ្ឌលគិរី ឆ្នាំ២០២១-២០៣៥, និង**ទី៤).** កំពុងរៀបចំបញ្ចប់ “ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២២-២០៣៥”។ ផ្តើមចេញពីឯកសារផែនទីចង្អុលផ្លូវ និងដោយអនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ឡើងវិញ, រាជរដ្ឋាភិបាលបានអនុម័តដាក់ចេញនូវឯកសារដ៏មានសារៈសំខាន់ **២** ទៀត រួមមានៈ **ទី១-វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ២០២១-២០២៣** និង **ទី២-ផែនការយុទ្ធសាស្ត្រ ស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង** ដែលបានក្លាយជាឯកសារយុទ្ធសាស្ត្រដ៏សំខាន់ សម្រាប់ការបើកឱ្យដំណើរការឡើងវិញនៃការទទួលទេសចរអន្តរជាតិមកកម្ពុជា។

*- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីរាប់អាន*
*- អង្គសន្និបាតជាទីមេត្រី!*

ខណៈដែលវិបត្តិនៃជំងឺកូវីដ-១៩ នៅកម្រិតសកលកំពុងថមថយ, វិស័យទេសចរណ៍អន្តរជាតិចាប់ផ្តើមមានសន្ទុះងើបឡើងវិញ ដោយប្រទេសភាគច្រើនបានបន្ធូរបន្ថយនូវវិធានការរឹតត្បិត និងការដករបាំងដែលជាលក្ខខណ្ឌតម្រូវនានាលើការធ្វើដំណើរជាអន្តរជាតិ។ នៅ**ឆ្នាំ២០២២** នេះ វិស័យទេសចរណ៍សកលលោករំពឹងថានឹងមានភាពល្អប្រសើរជាងកាលពីឆ្នាំ២០២០ និង២០២១ ដោយសារការចាប់ផ្តើមកម្រើកឡើងវិញនៃចរន្តនៃការធ្វើដំណើររបស់ភ្ញៀវទេសចរអន្តរជាតិ ជាមួយនឹងការកើនឡើងនៃតម្រូវការក្នុងការធ្វើដំណើរដើម្បីជួបជុំគ្រួសារ ការធ្វើធុរកិច្ច និងការកម្សាន្ត ក្រោយពីខកខានអស់មួយរយៈ ដោយសារការដាក់ចេញនូវវិធានការរឹតត្បិតនានា និងការបិទខ្ទប់នៅអំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩។

តាមការព្យាកររបស់**អង្គការទេសចរណ៍ពិភពលោក** (UNWTO) ចំនួនទេសចរអន្តរជាតិក្នុងឆ្នាំ២០២២ នេះ អាចនឹងថយចុះក្នុងចន្លោះពី -៣០% ទៅ -៤៥% បើធៀបនឹងចំនួនទេសចរអន្តរជាតិនៅក្នុងឆ្នាំ២០១៩ (មុនវិបត្តិ) ដោយសារតែវិស័យទេសចរណ៍សកលលោកកំពុងទទួលរងការគំរាមកំហែង និងផលប៉ះពាល់ជាអវិជ្ជមានពីវិបត្តិ និងបញ្ហាប្រឈមនានា ដូចជា ការវិវត្តជាបន្តបន្ទាប់នៃមេរោគកូវីដ-១៩ បំប្លែងថ្មី និងជំងឺឆ្លងផ្សេងៗ, វិបត្តិនៅអ៊ុយក្រែន ដែលបានជះឥទ្ធិពល ធ្វើឱ្យមានការកើនឡើងនូវអតិផរណាជារួម, ការកើនឡើងខ្លាំងនៃថ្លៃប្រេង និងការថមថយអំណាចទិញរបស់ភ្ញៀវ, ល្បឿនខុសៗគ្នានៃការបន្ធូរបន្ថយការរឹតត្បិតលើការធ្វើដំណើរ និងរបាំងនានារបស់ប្រទេសនីមួយៗ ជាដើម។

ចំពោះកម្ពុជា ដោយឈរលើភាពជោគជ័យដ៏ត្រចះត្រចង់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ តាមរយៈយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតភាពស៊ាំសហគមន៍នៅទូទាំងប្រទេស រួមជាមួយនឹងការអនុវត្តនូវវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការអន្តរាគមន៍នានា ចំគោលដៅ និងបានទាន់ពេលវេលា, រាជរដ្ឋាភិបាលបានសម្រួលលក្ខខណ្ឌសម្រាប់ភ្ញៀវទេសចរ និងអ្នកដំណើរអន្តរជាតិ ក្នុងការចូលមកកម្ពុជា ជាបន្តបន្ទាប់ ពិសេសការសម្រេចបើកការធ្វើដំណើរតាមច្រកទ្វារអន្តរជាតិទាំងអស់ឡើងវិញ និងផ្តល់ទិដ្ឋាការនៅពេលមកដល់ (Visa on arrival) ដោយលុបចោលលក្ខខណ្ឌតម្រូវឱ្យបង្ហាញលទ្ធផល PCR តេស្តអវិជ្ជមាន និងមិនតម្រូវឱ្យធ្វើតេស្តរហ័សនៅពេលមកដល់ចំពោះភ្ញៀវដែលបានចាក់វ៉ាក់សាំងគ្រប់ដូស ហើយចុងក្រោយនេះ បានសម្រេចអនុញ្ញាតលើកលែងការធ្វើចត្តាឡីស័កចំពោះភ្ញៀវទេសចរជាតិ អន្តរជាតិ ដែលមិនទាន់បានចាក់វ៉ាក់សាំង ឬមិនទាន់ចាក់វ៉ាក់សាំង បានគ្រប់ដូស ដោយគ្រាន់តែតម្រូវឱ្យធ្វើតេស្តរហ័ស នៅច្រកចេញ-ចូល ពេលមកដល់ប្រទេសកម្ពុជា។ ជាលទ្ធផល

ការកាត់បន្ថយនូវរបាំងនៃការធ្វើដំណើរទាំងនេះ និងការគ្រប់គ្រងបានយ៉ាងល្អ បានធ្វើឱ្យមានកំណើនចំនួននៃការធ្វើដំណើររបស់ភ្ញៀវទេសចរផ្ទៃក្នុង ព្រមទាំងចំនួននៃការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិក៏មានការកើនឡើងផងដែរ ហើយជើងហោះហើរចូលមកកម្ពុជា ក៏មានការកើនឡើងជាបន្តបន្ទាប់គួរឱ្យកត់សម្គាល់។

ជាក់ស្តែង សម្រាប់រយៈពេល**៦ខែដើមឆ្នាំ២០២២** កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណជាង **៥០ម៉ឺននាក់** កើនឡើង **៣៩៤**% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ តែនៅថយចុះ-**៨៤.៨**% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩ (មុនវិបត្តិ) ដោយភាគច្រើនមកពីប្រភពទីផ្សារ ដូចជា វៀតណាម, ថៃ, ចិន, សហរដ្ឋអាមេរិក, ឥណ្ឌូណេស៊ី, បារាំង, កូរ៉េ, ម៉ាឡេស៊ី, អង់គ្លេស, អូស្ត្រាលី, សិង្ហបុរី, និងឥណ្ឌា។ រីឯភ្ញៀវទេសចរផ្ទៃក្នុងធ្វើដំណើរកម្សាន្តក្នុងប្រទេសរួមមានៈ ទេសចរជាតិសរុបប្រមាណ **៦,៣៣** លាននាក់ កើនឡើងក្នុងអត្រាប្រមាណ **២១៩**% និងទេសចរបរទេសផ្ទៃក្នុងប្រមាណ **៦៨ ម៉ឺននាក់** កើនឡើងក្នុងអត្រាប្រមាណ **៣៨០**% ធៀបរយៈពេលដូចគ្នាឆ្នាំ២០២១។

ឈរលើមូលដ្ឋាននៃការកម្រើកឡើងវិញនៃចរន្តទេសចរណ៍សកលលោក ក៏ដូចជាទេសចរណ៍តំបន់ ជាមួយនឹងកិច្ចអន្តរាគមន៍ប្រកបដោយស្មារតីបុរេសកម្មរបស់រាជរដ្ឋាភិបាល កម្ពុជារំពឹងថានឹងអាចទទួលបានភ្ញៀវទេសចរអន្តរជាតិ ក្នុងរង្វង់ប្រមាណ **១លាននាក់** នៅក្នុង**ឆ្នាំ២០២២** នេះ ហើយនិងប្រមាណ **២លាននាក់** នៅក្នុង**ឆ្នាំ២០២៣** ខាងមុខ ជាឆ្នាំដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ**ព្រឹត្តិការណ៍កីឡាស៊ីហ្គេម-អាស៊ានប៉ារ៉ាហ្គេម លើកទី៣២**។

- *ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីរាប់អាន*
- *អង្គសន្និបាតជាទីមេត្រី!*

ខ្ញុំសូមបញ្ជាក់ថា អង្គសន្និបាតនាពេលនេះនឹងដំណើរការរយៈពេល ៤ពេល ដោយផ្តោតលើប្រធានបទសំខាន់ៗចំនួន ០៤ រួមមានៈ

**ប្រធានបទទី១: វឌ្ឍនភាពនៃការអនុវត្តផែនទីចង្អុលផ្លូវ ស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ ក្នុង និងក្រោយដំណាក់កាលវិបត្តិជំងឺកូវីដ-១៩**

**ប្រធានបទទី២: ការស្តារឡើងវិញផ្នែកសេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍**

**ប្រធានបទទី៣: ការជំរុញចលនាទេសចរណ៍ក្នុងស្រុក**

**ប្រធានបទទី៤: ការសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍តាមច្រកទ្វារអន្តរជាតិ**

ដើម្បីបានជាមូលដ្ឋានសម្រាប់កិច្ចពិភាក្សាក្នុងអង្គសន្និបាតនាពេលបន្តិចទៀតនេះ ខ្ញុំសូមលើកឡើងនូវសំណួរគន្លឹះសំខាន់ៗមួយចំនួន ដូចខាងក្រោមៈ

**ទី១.** តើនៅក្នុងបរិបទចំពោះមុខនេះ ក្រសួងទេសចរណ៍ និងអង្គភាពក្រោមចំណុះ, ក្រសួង ស្ថាប័នពាក់ព័ន្ធ, ផ្នែកឯកជន, និងប្រជាពលរដ្ឋ ត្រូវផ្តល់អាទិភាពដល់ការងារអ្វីជាចាំបាច់ និងចូលរួមយ៉ាងដូចម្តេចខ្លះ ដើម្បីជំរុញការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាពីវិបត្តិជំងឺកូវីដ-១៩?

**ទី២.** កម្ពុជាមានការប្រកួតប្រជែងកាន់តែស្រួចស្រាលជាមួយនឹងគោលដៅនានាក្នុងតំបន់ ដូច្នេះ តើកម្ពុជាត្រូវពង្រឹងលក្ខណសម្បត្តិបែបណាខ្លះបន្ថែមទៀត ទាំងលើទិដ្ឋភាពនៃការអភិវឌ្ឍផលិតផល និងសេវាកម្មទេសចរណ៍ថ្មី, ការពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍ដែលមានស្រាប់, ការជំរុញការងារផ្សព្វផ្សាយក្នុងប្រទេស ក៏ដូចជាលើឆាកអន្តរជាតិ?

**ទី៣.** ស្របពេលជាមួយនឹងការអនុវត្តផែនទីចង្អុលផ្លូវនេះ តើបច្ចុប្បន្នយើងគួរមានការយកចិត្តទុកដាក់លើអ្វីថ្មីបន្ថែមទៀត ស្របតាមការវិវត្តយ៉ាងឆាប់រហ័សនៃសភាពការណ៍ទេសចរណ៍ក្នុងកម្រិតសកលលោក និងតំបន់ ក៏ដូចជាស្ថានភាពសេដ្ឋកិច្ច សង្គម ដែលមានភាពប្រទាក់ក្រឡាគ្នាជាមួយនឹងដំណើរនៃការអភិវឌ្ឍវិស័យទេសចរណ៍?

**ទី៤.** តើអ្វីខ្លះដែលជាចលករសំខាន់ក្នុងការជំរុញការធ្វើដំណើរក្នុងស្រុករបស់ភ្ញៀវទេសចរជាតិ និងទេសចរបរទេសផ្ទៃក្នុងឱ្យបានកាន់តែផុលផុស ជាពិសេសជំរុញឱ្យមានការចំណាយឱ្យបានកាន់តែច្រើន?

**ទី៥.** យើងឃើញថាជាមួយនឹងការបើកទទួលស្វាគមន៍ភ្ញៀវទេសចរអន្តរជាតិឡើងវិញ ដើម្បីមានលទ្ធភាពទាក់ទាញភ្ញៀវពីទីផ្សារគោលដៅ កម្ពុជាពិតជាត្រូវការចាំបាច់នូវការតភ្ជាប់ពីអន្តរជាតិ, តើយើងគួរធ្វើដូចម្តេចបន្ថែមទៀតដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍ឱ្យបានកាន់តែប្រសើរ?

ខ្ញុំសូមសំណូមពរឱ្យអង្គសន្និបាតទាំងមូលយកចិត្តទុកដាក់ធ្វើការពិភាក្សា ផ្លាស់ប្តូរយោបល់គ្នាឱ្យបានផុលផុសពីគ្រប់ភាគីពាក់ព័ន្ធ ទាំងមន្ត្រីទេសចរណ៍គ្រប់កម្រិត គ្រប់ថ្នាក់ និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន ដើម្បីទទួលបានទស្សនៈ និងធាតុចូលថ្មីៗបន្ថែមទៀតក្នុងការស្វែងរកវិធានការគន្លឹះនានាដែលជាទិសដៅការងារសំខាន់សម្រាប់ការអនុវត្តបន្ត។

***- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីរាប់អាន***
***- អង្គសន្និបាតជាទីមេត្រី!***

មុននឹងបញ្ចប់ ខ្ញុំសូមកោតសរសើរ និងថ្លែងអំណរគុណចំពោះក្រសួង-ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ផ្នែកឯកជន អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជានិច្ចកាលបានចូលរួមសហការជាមួយក្រសួងទេសចរណ៍ គាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ប្រកបដោយការយកចិត្តទុកដាក់ ស្មារតីទទួលខុសត្រូវ និងប្រុងប្រយ័ត្នខ្ពស់។

ខ្ញុំសង្ឃឹមថាអង្គសន្និបាតទាំងមូល នឹងទទួលបានលទ្ធផលល្អប្រសើរ ពិសេសនឹងទទួលបានអនុសាសន៍ណែនាំដ៏ថ្លៃថ្លាបន្ថែមទៀត របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុង**ពិធីបិទសន្និបាត** នៅព្រឹកថ្ងៃខានស្អែកនេះ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ**ឯកឧត្តម លោកជំទាវ លោក លោកស្រី** សូមប្រកបតែនឹងសេចក្តីសុខ និងជ័យជំនះគ្រប់ប្រការ និងសូមទទួលបាននូវពុទ្ធពរទាំង ៥ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើក**សន្និបាតបូកសរុបការងារទេសចរណ៍ ការបូកសរុបផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ដំណាក់កាលទី១ (២០២០-២០២១) និងឆមាសទី១ ឆ្នាំ២០២២ និងលើកទិសដៅផែនការស្តារឡើងវិញនូវវិស័យទេសចរណ៍ក្នុងដំណាក់កាលទី២ (ឆមាសទី២ ឆ្នាំ ២០២២-២០២៣)** ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***